# ភ្លក់អាហារឆ្ងាញ់នៅភ្នំពេញ

# Dim Sum Emperors & Blue Pumpkin សាខាបឹងកេងកង១







១.បាយទាខ្វៃពងទាប្រៃ ២. ស៊ុបចិនសៃសាច់ជ្រូក ៣. បរិយាកាសក្នុងហាង ៤. ស៊ីវម៉ៃស្ងួលសាច់ជ្រូក និងហាការ

ចង់ញុំា Dim Sum រសជាតិពិតមកពីហុងកុងដែរឬទេ? Dim Sum Emperors នៅផ្លូវលេខ៥៧ សង្កាត់បឹងកេងកង១ ស្ថិតនៅជាន់ទី២នៃអគារ Blue Pumpkin ជាសាខាទី៤ក្នុងចំណោម ៧សាខានៅក្រុងភ្នំពេញ និងសៀមរាប ទើបបើកសម្ពោធថ្មីកាលពីខែកុម្ភៈកន្លងមកថ្មីៗនេះ។ Dim Sum Emperors មានលក់ម្ហូបចិនដែលមានចុងភៅមកពីប្រទេសហុងកុង នាំយករសជាតិពិតៗ មកជូនអតិថិជនយើងនៅកម្ពុជា។ លោកអ្នកអាចជ្រើសរើសមុខម្ហូប បង្អែម និងភេសជ្ជៈក្នុង Menu សរុបប្រមាណជា១០០មុខ ដែលភាគច្រើនជាម្ហូបសុខភាព ដូចជាស៊ុបចិនសៃសាច់ជ្រូកជាដើម។ រាល់មុខម្ហូបទាំងអស់សុទ្ធតែសម្រិតសម្រាំងឡើង យ៉ាងយកចិត្តទុកដាក់បំផុតពីមេចុងភៅហុងកុង ជាពិសេស Dim Sum ដោយគេមាន Central Kitchen សម្រាប់គ្រប់គ្រងគុណភាព និងរសជាតិជាប្រចាំ មុននឹងដឹកជញ្ជូនចែកចាយទៅតាមរាល់សាខានីមួយៗជារៀងរាល់ថ្ងៃ។

ចាប់ផ្ដើមល្បីល្បាញខាង Dim Sum ពីសាខាទី១ដែលបើកតំបូងគេបង្អស់នៅទីតាំងផ្សារធំថ្មីនៅ ឆ្នាំ២០១៣។ អតិថិជនជាច្រើន ជាពិសេសជនជាតិចិន និងខ្មែរតែងតែសរសើរមិនដាច់ពីមាត់ពីរសជាតិដ៏ឆ្ងាញ់នៃ Dim Sum និងមុខម្ហូបចិនផ្សេងៗទៀត។ ចាប់តាំងពីពេលនោះ Dim Sum Emperors កាន់តែមានអតិថិជនច្រើនឡើងៗ រហូតដល់ពង្រីកសាខាចំនួន៧កន្លែង រហូតមកដល់បច្ចុប្បន្ន ហើយក៏មានគម្រោងនឹងពង្រីកឲ្យបានដល់១០សាខានាអនាគតខ្លីខាងមុខនេះ។

ពេលនេះយើងសូមលើកយកមុខម្ហូបពេញនិយមប្រចាំហាងមួយចំនួនមកបង្ហាញជូន។ ហាការ ជា Dim Sum ស្ងួលសាច់ជ្រូក និងបង្គា (តម្លៃ៣,៣០ដុល្លា មាន៤ដុំ) គ្រាន់តែខាំ១ម៉ាត់ យើងទទួលរសជាតិដ៏ស្រស់នៃសាច់បង្គា និងសាច់ជ្រូកចិញ្ច្រាំនោះភ្លាម។ ស៊ីវម៉ៃស្ងួលសាច់ជ្រូកនិងបង្គាដាក់ពងត្រីពីលើ (តម្លៃ២,៩០ដុល្លា មាន៤ដុំ)។ នំប៉ាវស្ងួលត្រាវ (តម្លៃ៣,៣០ដុល្លា មាន៤ដុំ) សាច់នំទន់ល្មើយ ឯស្នូលផ្អែមតិចៗ។ អាហារដែលរៀបរាប់ខាងលើ អតិថិជនភាគច្រើនមកទទួលទានជាលក្ខណៈក្រុមគ្រួសារ និងមិត្តភ័ក្តិសម្រាប់អាហារពេលព្រឹក។ ចំណែកអាហារថ្ងៃត្រង់ដើម្បីសុខភាពកាន់តែរឹងមាំថែមទៀតនោះ គឺស៊ុបចិនសៃសាច់ជ្រូក (តម្លៃ៤,៥០ដុល្លា) និងបាយទាខ្វៃពងទាប្រៃ (តម្លៃ៣,៨០ដុល្លា)។ លើសពីនេះទៅទៀត លោកអ្នកក៏អាចរកទិញទាខ្វៃទាំងមូលបែបប៉េកាំងសម្រាប់ខ្ចប់យកចេញផងដែរ ដោយតម្លៃតែ១២,៨០ដុល្លាប៉ុណ្ណោះ។

ក្រៅពីរសជាតិ កន្លែងទទួលទានក៏មានផាសុកភាព និងប្រកបដោយអនាម័យជាមួយនឹងការតុបតែងក្នុងបរិយាកាសពណ៌ស និងក្រហមបែបហុងស៊ុយចិន។ សូមចំណាយពេលវេលាជាមួយក្រុមគ្រួសារ ឬមិត្តភ័ក្តិរបស់អ្នកនឹងអាហារដ៏ឆ្ងាញ់ពិសារនៅទីនេះ។

នៅជាន់ខាងក្រោមនៃ Dim Sum Emperors គឺជា Blue Pumpkin ដែលនរណាៗក៏ស្គាល់ថាជាហាងនំ និងភោជនីយដ្ឋានដ៏ល្បីល្បាញទាំងនៅទីក្រុងភ្នំពេញ និងសៀមរាបចាប់ផ្ដើមតាំងពី ឆ្នាំ២០០០ ហើយកាលពីឆ្នាំមុនគេទើបតែប្រារព្ធពិធីគំរប់ខួប១៥ឆ្នាំ។ ក្នុងឆ្នាំ២០១៦ ឆ្នាំថ្មីនេះ Blue Pumpkin បានបង្កើតសកម្មភាពថ្មីមួយទៀត គឺ Grab & Go ដែលផ្ដល់សេវាអាហារកាន់តែងាយស្រួល និងឆាប់រហ័សដល់អតិថិជន។ ចំពោះលោកអ្នកដែលមិនសូវមានពេលច្រើនក្នុងការអង្គុយទទួលទាន អាហារដែលរហ័សនៅ Grab & Go មានដូចជានំប៉ុងសាំងវិចរសជាតិច្រើនប្រភេទ សាឡាត់ ទឹកដោះគោជូ នំផ្អែម ការ៉េម និងភេសជ្ជៈ។




**Dim Sum Emperors** ម៉ោងបើក ០៧:០០-១៤:០០ / ១៧:០០-២១:០០
**Blue Pumpkin** ម៉ោងបើក ០៧:០០-២១:០០
ផ្លូវលេខ ៥៧កែងនឹង២៨៨ សង្កាត់បឹងកេងកង១ ក្រុងភ្នំពេញ។
ទូរស័ព្ទ ០១៥ ៧៥៧ ៧៧៦ / ០២៣ ៦៦៧ ១១៦៨